រដ្ឋលេខាធិការ ។

– ឯកឧត្តម ជា សោភ័ណ ទទួលបន្ទុកកិច្ចការរដ្ឋបាលមានឋានៈស្មើ អនុរដ្ឋលេខាធិការ ។

**មាត្រា ២** : នាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលជាតិកម្ពុជាត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** : ព្រះរាជក្រឹត្យចូលជាធរមានច្បាប់ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ១៩៩៥

ព្រះហស្តលេខា

**នរោត្តម សីហនុ**

* * *

# II- ទីស្តីការគណៈរដ្ឋមន្ត្រី

## ១—អនុក្រឹត្យ

ភ្នំពេញ , ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៥

**អនុក្រឹត្យ លេខ : ៥៧ អនក្រ.បក**

**ស្តីពីការបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេស**

* * *

**រាជរដ្ឋាភិបាល**

– បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
– បានឃើញច្បាប់ការងារដែលប្រកាសអោយប្រើដោយក្រឹត្យលេខ ៩៩ ក្រ ចុះថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ១៩៩២
– បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយ ប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
– បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទ សម្តេចព្រះ **នរោត្តម សីហនុ**

**ចរ្ន័ន** ព្រះមហា ក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណា ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ ចរ្ន័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

-តាមសំណើរបស់រដ្ឋលេខាធិការ ក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជន

**សំរេច**

មាត្រា ១ : ដើម្បីដោះស្រាយជីវភាព និង បង្កើនមុខជំនាញវិជ្ជាជីវៈ រាជរដ្ឋាភិបាលអនុញ្ញាតអោយបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេសនៅពេលដែលទីផ្សារ ការងារក្នុងប្រទេសមិនទាន់មានលទ្ធភាពទទួលយកអ្នកគ្មានការងារធ្វើ និង អ្នកដែលមានការងារធ្វើមិនពេញលេញបានអស់ និង រកប្រាក់ចំណូលចូលថវិកាជាតិ ។

មាត្រា ២ : ការបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេស និង ការគ្រប់គ្រងពលករទាំងនេះជាសមត្ថកិច្ចរបស់ក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជន ។

ក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជនអាចអនុញ្ញាតតាមប្រកាសរបស់ក្រសួងអោយក្រុមហ៊ុនណាមួយបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេសបាន ។

ក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជន ត្រូវចេញសារាចរណែនាំអនុវត្តបន្ថែម ទៀតក្នុងករណីចាំបាច់ ។

ក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជន ត្រូវសហការជាមួយក្រសួងមហាផ្ទៃក្នុងការធ្វើទំរង់បែបបទដូចជាលិខិតឆ្លងដែនជាដើម ដើម្បីបញ្ជូនពលករទៅបរទេស ហើយត្រូវសហការជាមួយក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ក្នុងការគ្រប់គ្រងពលករ ខ្មែរដែលធ្វើការនៅបរទេស ។

**មាត្រា ៣** : ត្រូវបានចាត់ទុកជាបេក្ខជនសំរាប់ជ្រើសរើសបញ្ជូនអោយទៅធ្វើការនៅបរទេស ពលករខ្មែរ ទាំងពីរភេទមានអាយុចាប់ពី ១៨ ឆ្នាំឡើងទៅ ដែលបានដាក់ពាក្យសុំរកការងារធ្វើនៅក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជន ។

**មាត្រា ៤** : ក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជន ហៅថាភាគីផ្តល់ពលករ ។
ក្រុមហ៊ុនដែលស្នើសុំជ្រើសរើសពលករ ហៅថាភាគីទទួលពលករ ។

**មាត្រា ៥** : រាល់សំណើពីភាគីទទួលពលករ ត្រូវបញ្ជាក់អោយច្បាស់លាស់អំពីល័ក្ខខ័ណ្ឌសំខាន់ ៗ ជាអាទិ៍ :

- កាលបរិច្ឆេទចាប់ផ្តើមអនុវត្ត និង បញ្ចប់ការងារ
- ប្រភេទការងារ
- ទីកន្លែងទៅធ្វើការងារ
- ចំនួន និង មុខជំនាញរបស់ពលករ
- ប្រាក់បៀវត្ស ប្រាក់បំណាច់ផ្សេង ៗ ដោយគិតទាំងការស្នាក់នៅ ហូបចុក ស្លៀកពាក់ព្យាបាល ព្រមទាំងបញ្ហាផ្សេង ៗ ទៀតក្នុងជីវភាពប្រចាំថ្ងៃ
- ការដឹកជញ្ជូនពលករទៅ និង មក ។

ក្រោយពីបានទទួលសំណើ ភាគីផ្តល់ពលករត្រូវឆ្លើយទៅភាគីទទួលពលករវិញយ៉ាងយូរបំផុត ៤៥ ថ្ងៃដោយត្រូវបញ្ជាក់ថា តើអាចផ្តល់ពលករបានក៏រិតណា ឬ មិនបាន ឬ ត្រូវពិភាក្សាគ្នាបន្ថែមទៀត ។

ភាគីទទួលពលករ ត្រូវឆ្លើយមកភាគីផ្តល់ពលករវិញយ៉ាងយូរ ៣០ ថ្ងៃ ថាតើត្រូវការពលករ ទាំងអស់នោះឬទេ ឬត្រូវការតែក៏រិតណាមួយនោះដោយត្រូវចូលមកពិភាក្សានៅពេលជាមួយគ្នានេះដែរ។ ហួសរយៈពេល ៣០ ថ្ងៃ ហើយបើគ្មានចម្លើយ និង មិនឃើញចូលមកពិភាក្សា ទេភាគីផ្តល់ពលករកំណត់ថា ភាគីទទួលពលករមិនត្រូវការពលករទាំងនោះទេ ។

**មាត្រា ៦** : ការបញ្ជូនពលករទៅបរទេសអាចអនុវត្តបាន លុះត្រាតែមានការអនុញ្ញាតពីភាគីផ្តល់ពលករ និងត្រូវមានកិច្ចសន្យាការងាររវាងពលករ ជាមួយភាគីទទួលពលករ ។

**មាត្រា ៧** : ក្រោយពេលទទួលការអនុញ្ញាតជាផ្លូវការរយៈពេល ៧ ថ្ងៃ យ៉ាងយូរ ភាគីទទួលពលករត្រូវតែតំកល់ប្រាក់ធានាចំនួនមួយរយពាន់ដុល្លារអាមេរិកនៅក្នុងគណនីរបស់ភាគីផ្តល់ពលករ ។

បើភាគីទទួលពលករមិនបានបង់ប្រាក់ធានានេះទេ ការអនុញ្ញាតនេះនឹងត្រូវចាត់ទុកជាមោឃៈ ។

ប្រាក់តំកល់នេះ សំរាប់អោយភាគីផ្តល់ពលករបើកអោយពលករ ជំនួសភាគីទទួលពលករក្នុងករណីដែលភាគីនេះ មិនបានគោរពល័ក្ខខ័ណ្ឌណាមួយដែលមានចែងក្នុងកិច្ចសន្យាការងារ ។

ក្នុងពេលអនុវត្តកិច្ចសន្យាការងារ បើប្រាក់តំកល់នេះត្រូវបានដកខ្លះ ដើម្បី អោយពលករភាគីទទួលពលករត្រូវបង់បំពេញអោយ បានគ្រប់ចំនួនឡើងវិញ។

ភាគីទទួលពលករអាចដកប្រាក់តំកល់នេះទៅវិញបាននៅពេលចប់កិច្ចសន្យាការងារជាស្ថាពរជាមួយពលករទាំងអស់ ។

ប្រាក់តំកល់ក្នុងមាត្រានេះ អាចបន្ធូរបន្ថយបានចំពោះនិយោជកដែលត្រូវការជ្រើសរើសពលករខ្មែរ តែបន្តិចបន្តួចដោយផ្ទាល់ ដើម្បីយក ទៅធ្វើការក្នុងរោងជាង ឬ រោងសិប្បកម្មរបស់ខ្លួន ។ ប៉ុន្តែនិយោជកនោះ ចាំបាច់ត្រូវពិភាក្សាជាមួយក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជន ដើម្បីធ្វើកិច្ចសន្យាឯកត្តភ្ជួតជាមួយពលករទាំងនោះ ។

**មាត្រា ៨ :** ភាគីទទួលពលករត្រូវបង់សោហ៊ុយសេវា និង ការរៀបចំឯកសារផ្សេង ៗ ជូនភាគីផ្តល់ពលករតាមការឯកភាពគ្នាដែលមានកំណត់ក្នុងកិច្ចសន្យា ។

**មាត្រា ៩ :** កិច្ចសន្យាការងារ ត្រូវបញ្ជាក់អោយច្បាស់ជាអាទិ៍ ÷

- ឈ្មោះ និង អាស័យដ្ឋានរបស់ភាគីនិមួយ ។
- កាលបរិច្ឆេទនៃការចាប់ផ្តើម និង បញ្ចប់កិច្ចសន្យា
- ទីកន្លែង និង ប្រភេទការងារជាក់ស្តែង
- [illegible]ញពលករ
- ប្រាក់បៀវត្ស និង ប្រាក់បំណាច់ផ្សេង ។
- ភាគបៀវត្ស និង ប្រាក់បំណាច់ផ្សេង ។ ដែលត្រូវបញ្ជូនមកគ្រួសារ
- ពេលម៉ោងធ្វើការ និង ថ្ងៃឈប់សំរាកប្រចាំសប្តាហ៍ ប្រចាំឆ្នាំ
- ការស្នាក់នៅ ហូបចុក ស្លៀកពាក់ ព្យាបាល
- ការបង់ប្រាក់ធានារ៉ាប់រងចំពោះពលករម្នាក់ ៗ
- ការប្រគល់ និង ទទួលពលករពេលទៅ និង ពេលត្រឡប់មកវិញ
- សោហ៊ុយដឹកជញ្ជូនពលករទៅ និង មក

– ករណីដែលត្រូវបញ្ជូនពលករមកមាតុប្រទេសវិញមុនកាលកំណត់ក្នុងកិច្ចសន្យាការងារ។

**មាត្រា១០** : ពលករទាំងអស់ត្រូវមានសិទ្ធិឈប់សំរាកប្រចាំឆ្នាំដោយមានប្រាក់ឈ្នួល ដែលភាគីទទួលពលករត្រូវចេញអោយ ។ ឯចំនួនថ្ងៃឈប់សំរាកនេះ ត្រូវគិតជាថ្ងៃធ្វើការធម្មតាមួយថ្ងៃកន្លះយ៉ាងតិចក្នុងរយៈពេលធ្វើការមួយខែជាប់ ។

**មាត្រា១១** : កិច្ចសន្យាការងារ ត្រូវធ្វើជាពីរភាសាដែលមានតំលៃស្មើគ្នា គឺ ភាសាខ្មែរ និង ភាសាបារាំងឬ អង់គ្លេស ។ រយៈពេលនៃកិច្ចសន្យាការងារមិនត្រូវអោយលើសពីរឆ្នាំឡើយ ។

នៅពេលចប់អាណត្តិនៃកិច្ចសន្យាការងារ ភាគីទាំងពីរអាចពិភាក្សាគ្នាបន្តអនុវត្តកិច្ចសន្យាទៅទៀតបាន ឬ មួយធ្វើកិច្ចសន្យាសាថ្មី ។ កិច្ចសន្យាបន្តការងារតទៅទៀត ឬ ធ្វើ សាជាថ្មីក៏ត្រូវមានការចុះទិដ្ឋាការសាថ្មីពីក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជនដែរ។

**មាត្រា១២** : ភាគីផ្តល់ពលករ ជាអ្នកជ្រើសរើសពលករតាមមុខជំនាញនីមួយ ៗ អោយបានគ្រប់ចំនួនដែលបានកំណត់ក្នុងកិច្ចសន្យាការងារ ។

កិច្ចសន្យាការងារ ដែលពលករចុះហត្ថលេខាជាមួយភាគីទទួលពលករត្រូវមានចុះទិដ្ឋាការរបស់អធិការការងារមានសមត្ថកិច្ច ។

**មាត្រា១៣** : នៅពេលចុះកិច្ចសន្យាការងារ ពលករម្នាក់ ៗ ត្រូវផ្តល់ ÷

| | |
|---|---|
| –ជីវប្រវត្តិសង្ខេបរបស់សាមីជនមានបិទរូបថត ៤ × ៦ សម | ២ សន្លឹក |
| –សំបុត្រថ្កោលទោស | ២ ច្បាប់ |
| –លិខិតបញ្ជាក់សុខភាព ដែលចេញអោយដោយនាយកដ្ឋានពេទ្យការងារ | ២ ច្បាប់ |
| –សេចក្តីចម្លងសញ្ញាប័ត្រ ឬ លិខិតបញ្ជាក់មុខជំនាញ « បើសិនជាមាន » | ២ ច្បាប់ |
| –សេចក្តីចម្លងលិខិតឆ្លងដែនរបស់សាមីជន | ២ ច្បាប់ |
| –ប័ណ្ណសុំការងារ | ១ ច្បាប់ |

**មាត្រា១៤** : មុនពេលចេញដំណើរទៅបរទេសភាគីផ្តល់ពលករ និង ទទួលពលករ ត្រូវទទួលបន្ទុករៀបចំធ្វើកម្មសិក្សាអំពីរបៀបរបបធ្វើការងារ របៀបរបបរស់នៅទំនៀមទំលាប់ប្រពៃណី និង ច្បាប់ទំលាប់ជាចាំបាច់របស់ប្រទេសទទួលពលករ ។

**មាត្រា១៥** : ប្រាក់បៀវត្សរបស់ពលករម្នាក់ ៗ ត្រូវជាប់ពន្ធតាមច្បាប់ជាធរមាន នៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា១៦** : ភាគីទទួលពលករ ត្រូវរ៉ាប់រងចេញសោហ៊ុយចំណាយ អោយមន្ត្រីរបស់ប្រទេសផ្តល់ពលករទៅបំពេញបេសកកម្ម ដើម្បីជូនពលករទៅដល់ប្រទេសទទួលពលករ ត្រួតពិនិត្យលក្ខខ័ណ្ឌការងារ ទីកន្លែងធ្វើការងារ និង ទីស្នាក់អាស្រ័យរបស់ពលករដែលបានកំណត់ក្នុងកិច្ចសន្យា ។

ភាគីផ្តល់ពលករ ត្រូវបញ្ជូនមន្ត្រីទៅពិនិត្យការ អនុវត្តន៍កិច្ចសន្យាការងារដល់ទីកន្លែងក្នុងរយៈពេលដែលចាំបាច់ ។

**មាត្រា១៧** : បើមានវិវាទការងារកើតឡើង ភាគីទទួលពលករត្រូវពិភាក្សា និង ដោះស្រាយជាមួយពលករភ្លាម ដោយផ្អែកទៅលើកិច្ចសន្យាការងារ ។ បើការពិភាក្សាគ្នានេះមិនអាចសំរុះសំរួលគ្នាបានទេនោះ គេត្រូវផ្តល់ពត៌មានភ្លាមទៅស្ថានឯកអគ្គរាជទូត ឬ បេសកម្មទូតរបស់ព្រះរាជាណាចក្រកម្ពុជាប្រចាំប្រទេសនោះ ដើម្បីចូលរួមដោះស្រាយ ។

**មាត្រា១៨** : ភាគីទទួលពលករ ត្រូវផ្តល់ពត៌មានដល់ភាគីផ្តល់ពលករអោយបាន ៤៥ ថ្ងៃមុនកាលបរិច្ឆេទនៃការវិលត្រឡប់មកមាតុប្រទេសវិញពិតប្រាកដរបស់ពលករ ។

ភាគីទទួលពលករ និង ភាគីផ្តល់ពលករត្រូវរៀបចំរួមគ្នាអំពីប្រតិទិននៃការធ្វើមាតុភូមិនិវត្តន៍របស់ពលករ ។

**មាត្រា១៩** : ការបាត់ខ្លួនរបស់ពលករនៅក្នុងរយៈពេលអនុវត្តកិច្ចសន្យាការងារ ភាគីទទួលពលករត្រូវផ្តល់ពត៌មានជាបន្ទាន់ដល់ស្ថានឯកអគ្គរាជទូត ឬ បេសកកម្មទូតរបស់ព្រះរាជាណាចក្រកម្ពុជាប្រចាំប្រទេសនោះ និង មកក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជន នៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា២០** : ជនណាដែលបញ្ជូនពលករខ្មែរ ទៅធ្វើការនៅបរទេសដោយល្មើសនឹងបទបញ្ញត្តិទាំងឡាយក្នុងអនុក្រឹត្យនេះត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន ។

**មាត្រា២១** : បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា២២** : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច

និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជនត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| ព្រះហស្តលេខានិងត្រា | ហត្ថលេខា និង ត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *

## ២—សេចក្តីសំរេច

រាជធានីភ្នំពេញ , ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ១៩៩៥

**សេចក្តីសំរេច លេខ ៥០ សសរ**

**ស្តីពីការបង្កើតគណៈកម្មការត្រួតពិនិត្យ និង**

**ដេញថ្លៃឈើដែលនៅសេសសល់ក្រោយខិសានបាន**

* * *

**រាជរដ្ឋាភិបាល**

បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

– បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលកម្ពុជា .

– បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាស អោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

– បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.១០៩៤.៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល .

– តាមការចាំបាច់របស់រាជរដ្ឋាភិបាល